នស/រកត/០៤១៦/៣៦៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ : បញ្ចប់មុខងារ ៖**

១- ឯកឧត្តម **គាត ឈន់** ជាឧបនាយករដ្ឋមន្ត្រីប្រចាំការ តាមសំណើរបស់សាមីឥស្សរជន

២- ឯកឧត្តម **ហោ ណាំហុង** ជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមសំណើរបស់សាមីឥស្សរជន ដោយរក្សាទុកមុខងារជា ឧបនាយករដ្ឋមន្ត្រី

៣- ឯកឧត្តម **អ៊ឹម ឈុនលឹម** ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់សាមីឥស្សរជន ។

**មាត្រា ២ : តែងតាំង ៖**

១- ឯកឧត្តម **ប្រាក់ សុខុន** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣- ឯកឧត្តម **ស៊ុន ចាន់ថុល** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

៤- ឯកឧត្តម **ជា សុផារ៉ា** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៥- ឯកឧត្តម **ហ៊ឹម ឆែម** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

៦- ឯកឧត្តម **មិន ឃិន** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៧- ឯកឧត្តម **អ៊ឹម សូស្តី** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៨- ឯកឧត្តម **វេង សាខុន** ជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៩- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** ជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

១០- ឯកឧត្តម **ប៉ាន សូរស័ក្តិ** ជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១- ឯកឧត្តម **ត្រាំ អ៊ីវតឹក** ជា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១២- ឯកឧត្តម **ឈិត សុខុន** ជា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

១៣- ឯកឧត្តម **ខូយ ឃុនហួរ** ជា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

១៤- ឯកឧត្តម **ប៉ាច ហមផាន** ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

១៥- ឯកឧត្តម **ឡៅ អំ** ជា រដ្ឋលេខាធិការក្រសួងការពារជាតិ

១៦- ឯកឧត្តម **អ៊ី ឈាន** ជា រដ្ឋលេខាធិការក្រសួងការពារជាតិ

១៧- ឯកឧត្តម **លុយ ដាវីត** ជា រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១៨- ឯកឧត្តម **ណៅ ធូក** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៩- ឯកឧត្តម **លី ផល្លា** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២០- ឯកឧត្តម **ហាស់ សារ៉េត** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២១- ឯកឧត្តម **អ៊ូ សំអួន** ជា រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ

២២- ឯកឧត្តម **ផៃ ប៊ុនឈឿន** ជា រដ្ឋលេខាធិការក្រសួងបរិស្ថាន

២៣- ឯកឧត្តម **គោស៊ុំ សារឿត** ជា រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម

២៤- ឯកឧត្តម **ផែង សុទិដ្ឋារោ** ជា រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

២៥- ឯកឧត្តម **ជួន ចន** ជា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត.០៤១៦.៣៧៣*

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦

លេខ: ៣៦០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**